ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការជាតិសុខភាព
និងសុវត្ថិភាពការងារ
លេខ ០០៣/១៨ គ.ជ.ស.ក

ថ្ងៃ ច័ន្ទ ១៤ កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៨

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសសិក្សាស្រាវជ្រាវលើករណីដួលសន្លប់

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
## និងជាប្រធានគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៣៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ
- យោងលិខិតបង្គាប់ការលេខ០២២សខល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសុខាភិបាល

- យោងសេចក្ដីសម្រេចលេខ០០២គ.ជ.ស.ក/១៨ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

# សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសសិក្សាស្រាវជ្រាវលើករណីដួលសន្លប់សម្រាប់ជាសេនាធិការឱ្យក្រុមការងារសិក្សាស្រាវជ្រាវ ផ្ដល់យោបល់ ទប់ស្កាត់ករណីដួលសន្លប់របស់កម្មករនិយោជិតនៅតាមសហគ្រាស គ្រឹះស្ថានដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯ.ឧ សាស្ត្រាចារ្យ | **អេង ហួត** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សហប្រធាន |
| ២-ឯកឧត្ដមវេជ្ជ. | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សហប្រធាន |
| ៣-ល.ជ សាស្ត្រាចារ្យ | **អ៊ឹ សាម៉ុល** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤-ឯ.ឧ សាស្ត្រាចារ្យ | **ឈួយ ម៉េង** | ទីប្រឹក្សាក្រសួងសុខាភិបាល | សមាជិក |
| ៥-លោកជំទាវវេជ្ជ. | **ឱ វណ្ណឌីន** | អគ្គនាយកបច្ចេកទេសសុខាភិបាល | សមាជិកា |
| ៦-ឯ.ឧសាស្ត្រាចារ្យ | **សាផុន វឌ្ឍនះ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ៧-លោកជំទាវ | **ជា សុខនី** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិកា |
| ៨-លោកជំទាវ | **ម៉ៅ ធីតា** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ | សមាជិកា |
| ៩-ឯកឧត្ដម | **ឡេង តុង** | ទីប្រឹក្សាអមក្រសួង និងជាប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១០-ឯកឧត្ដម | **ស៊ុំ សោភ័ណ្ឌ** | ទីប្រឹក្សាអមក្រសួង និងជានាយករងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ១១-ឯកឧត្ដមវេជ្ជ. | **យី ភក្ដិដ្ឋា** | ទីប្រឹក្សាអមក្រសួងនិងជាអនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១២-ល.សាស្ត្រាចារ្យរង | **ឈា ឆវណ្ណា** | នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក |
| ១៣-លោកវេជ្ជ. | **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន | សមាជិក |
| ១៤-លោកវេជ្ជ. | **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ១៥-លោកវេជ្ជ. | **តាន់ សុគុន** | នាយកមន្ទីរពេទ្យព្រះកុសុមៈ | សមាជិក |
| ១៦-លោកវេជ្ជ. | **លី សូវ៉ាន់** | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ១៧-លោកឱសថការី | **ទេព កីឡា** | នាយកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិក |

| | | | |
|---|---|---|---|
| ១៨-លោកវេជ្ជ. | **ទ៉ូច ភាច** | អនុប្រធាននាយកដ្ឋានការពារសុខភាព | សមាជិក |
| ១៩-លោក | **ខេម ម៉ិនឈាន** | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ២០-លោក | **ខេង សំបូរ** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ២១-លោកវេជ្ជ. | **ហាន់ នព្វគុណ** | អនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ២២-លោកស្រីវេជ្ជ. | **ពេជ្រ ស្មាសិរី** | អនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិកា |
| ២៣-លោកវេជ្ជ. | **ឈុន ឡាយ** | ឯកទេសជំងឺបេះដូងនៃមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ២៤-លោកវេជ្ជ. | **ឧត ម៉ូឡារី** | ប្រធានការិ.ធានារ៉ាប់រងសុខភាពនៃប.ស.ស | សមាជិក |
| ២៥-កញ្ញាវេជ្ជ. | **ស្គុន រដ្ឋា** | ប្រធានការិយាល័យស្ថិតិ និងទំនាក់ទំនងខាងក្រៅ នៃនាយកដ្ឋានពេទ្យការងារ | សមាជិកា |
| ២៦-លោក | **ក្លូច ម៉ិនធឿន** | ប្រធានការិយាល័យអាស៊ានអូស្តណេត នៃនាយកដ្ឋានពេទ្យការងារ | សមាជិក |
| ២៧-លោកវេជ្ជ. | **គី ម៉ាលី** | អនុប្រធានការិយាល័យអាស៊ានអូស្តណេត នៃនាយកដ្ឋានពេទ្យការងារ | សមាជិក |
| ២៨-លោកវេជ្ជ. | **យ៉ុត សុភារ៉ា** | អនុប្រធានការិយាល័យអាស៊ានអូស្តណេត នៃនាយកដ្ឋានពេទ្យការងារ | សមាជិក |
| ២៩-លោក | **ថៃ ហេងដា** | អនុប្រធានការិយាល័យឯកសារសុខភាពការងារ នៃនាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៣០-លោកស្រី | **ផន សុផារី** | តំណាងអង្គការសុខភាពពិភពលោក | សមាជិកា |
| ៣១-លោក | **ទុន សុភ័ណ** | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៃអង្គការ ILO | សមាជិក |
| ៣២-លោកស្រី | Esther Germans | ប្រធានគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការ ILO | សមាជិកា |

**ប្រការ ២.-**

ក្រុមការងារបច្ចេកទេសនេះមានភារកិច្ចៈ

- ចុះត្រួតពិនិត្យស្ថានភាពរបស់គិលានដ្ឋាននៅតាមសហគ្រាស គ្រឹះស្ថានក្នុងការឆ្លើយតបទៅនឹងការបង្ការ និងការដួលសន្លប់ ឬគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- ចុះធ្វើការស្រាវជ្រាវរកមូលហេតុនៃការដួលសន្លប់ក្នុងអំឡុងពេលមានការដួលសន្លប់
- ធ្វើការសិក្សាស្រាវជ្រាវលើទិដ្ឋភាពទូទៅនៃការដួលសន្លប់ និងកត្តាដែលមានទំនាក់ទំនងនឹងការដួលសន្លប់
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ
- រៀបចំអនុសាសន៍សម្រាប់ទប់ស្កាត់ការដួលសន្លប់ និងបង្ការគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- សហការ និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ អង្គការនិយោជក អង្គការកម្មករនិយោជិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីវិធានការការពារករណីដួលសន្លប់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ ទប់ស្កាត់ករណីដួលសន្លប់របស់កម្មករនិយោជិតនៅតាមសហគ្រាស គ្រឹះស្ថានប្រគល់ជូន។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នាយកបេឡាជាតិរបបសន្តិសុខសង្គម និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី និងជាប្រធាន**
**គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ**

**អ៊ិត សំហេង**

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ